**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អគ្គនាយកដ្ឋានពន្ធដារ**
**នៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**
លេខ...១៧៧៧៤...អពដ

រាជធានីភ្នំពេញ, ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ២០១២

# សេចក្តីជូនដំណឹង
## ស្តីពី
## ការពង្រឹងការបង់ពន្ធរបបម៉ៅការ
## នៅស្នាក់ការពន្ធដារក្រុង-ស្រុក និងសាខាពន្ធដារខេត្ត-ខណ្ឌ

អគ្គនាយកដ្ឋានពន្ធដារ មានកិត្តិយសសូមជម្រាបជូនដំណឹងដល់អស់លោក-លោកស្រី ជាអាជីវករដែលបានជាប់ពន្ធតាមរបបម៉ៅការនៅរាជធានី-ខេត្ត មេត្តាជ្រាបថា កន្លងមកក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានចេញនូវសេចក្តីជូនដំណឹងលេខ ០១៩ សហវ ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការប្រមូល និងបង់ប្រាក់ពន្ធសម្រាប់អ្នកជាប់ពន្ធតាមរបបម៉ៅការ ។ អគ្គនាយកដ្ឋានពន្ធដារសង្កេតឃើញថា មានអាជីវករជាប់ពន្ធតាមរបបម៉ៅការមួយចំនួនធំនៅក្រុង-ស្រុកនៃខេត្ត និងខណ្ឌនៃរាជធានីភ្នំពេញ បានមកបង់ពន្ធប្រចាំខែយ៉ាងទៀងទាត់ និងទាន់ពេលវេលា នៅតាមបណ្តាស្នាក់ការពន្ធដារក្រុង-ស្រុក ឬសាខាពន្ធដារខេត្ត-ខណ្ឌ ដែលអាជីវកម្មដ្ឋានរបស់ខ្លួនស្ថិតនៅទីនោះ ។

ទន្ទឹមនឹងនេះ ក៏នៅសង្កេតឃើញអាជីវករមួយចំនួនតូចនៅអែអង់ និងគេចវេះមិនមកបង់ពន្ធ ដែលជាហេតុនាំឱ្យមានបំណុលពន្ធត្រូវទារយោងទៅខែមុខជាបន្តបន្ទាប់ ។ ក្នុងគោលបំណងរក្សាបាននូវភាពថ្លៃថ្នូររបស់ពលរដ្ឋក្នុងការបំពេញកាតព្វកិច្ចសារពើពន្ធ និងរក្សាបាននូវសន្តិសុខ ស្មេរភាពសាច់ប្រាក់ ដើម្បីបង់ចូលថវិការដ្ឋទាន់ពេលវេលា អគ្គនាយកដ្ឋានពន្ធដារសូមធ្វើការពង្រឹងអំពីការបង់ប្រាក់ពន្ធរបស់អ្នកជាប់ពន្ធតាមរបបម៉ៅការទាំងអស់ សូមរួសរាន់មកបង់ប្រាក់ពន្ធសម្រាប់ខែជាប់ពន្ធរបស់ខ្លួន នៅចុងខែនីមួយៗបានជាប់ជាប្រចាំ នៅបេឡាស្នាក់ការពន្ធដារក្រុង-ស្រុក ឬបេឡាសាខាពន្ធដារខេត្ត-ខណ្ឌ ទៅតាមការណែនាំរបស់អង្គភាពពន្ធដារនៅទីនោះ។

ការបង់ប្រាក់ពន្ធយឺតយ៉ាវនឹងត្រូវរងទោសទណ្ឌតាមច្បាប់ស្តីពីសារពើពន្ធជាធរមាន ។

ក្រោយទទួលបានសេចក្តីជូនដំណឹងនេះ អគ្គនាយកដ្ឋានពន្ធដារសង្ឃឹមយ៉ាងមុតមាំថា លោក លោកស្រី ដែលជាអាជីវករទាំងអស់ មានស្មារតីយោគយល់ និងអនុវត្តតាមការណែនាំខាងលើបានល្អប្រសើរដោយស្មារតីទទួលខុសត្រូវខ្ពស់ ។

**ប្រតិភូរាជរដ្ឋាភិបាល**
**ទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ**

អគ្គនាយកដ្ឋាន
ពន្ធដារ

**គង់ វិបុល**

អាគារកែងមហាវិថី សហព័ន្ធរុស្សី (១១០) និងម៉ៅសេទុង (២៤៥) សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ ទូរស័ព្ទ: (៨៥៥) ២៣ ៨៨៦ ៧០៨/ ទូរសារ: (៨៥៥) ២៣ ៨៨៦ ៧០០
CORNER RUSSIAN FEDERATION & MAO TSETONG BLVD. TOEK LAAK 1, TOUL KAUK, PHNOM PENH Phone: (855) 23 886 708/ Fax: (885) 23 886 700